# គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY

បំរើ ការពារ កសាង

**កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ**

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍ ថ្ងៃសុក្រ ទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ព្រឹត្តិប័ត្រលេខ៧១ ឆ្នាំទី២*



| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងកម្មករជិត១០០០នាក់ គោរពវិញ្ញាណក្ខន្ធលោក ជា វិជ្ជា | ១ |
| -កម្មករជាង៧០០០នាក់ធ្វើកូដកម្មទាមទារប្រាក់ខែទី១៣ពីថៅកែរោងចក្រ | ២ |
| -ឆ្នាំ២០០៨កំណើនវិវាទដីធ្លីនៅខេត្តកំពតមានការកើនឡើង | ២ |
| -អាជ្ញាធរនៅតែមានការរើសអើងនិងប្រកាន់និន្នាការនយោបាយ | ៣ |
| -ប្រជាពលរដ្ឋជាង២០០គ្រួសាររងការបាត់បង់ដីធ្លី | ៤ |


## គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងកម្មករជិត១០០០នាក់ គោរពវិញ្ញាណក្ខន្ធលោក ជា វិជ្ជា

លោក **ជា មុន្នី** ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងទៅកាន់ក្រុមអ្នកសារពត៌មានជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិល អ្នកនយោបាយ និងកម្មករជិត ១០០០នាក់ថា យើងនៅតែទទូចជានិច្ចឱ្យរដ្ឋាភិបាលកម្ពុជា រើកមុខឃាតករ ដោយលោកជឿថា ឃាតករនៅមានសេរីភាពនៅឡើយទេ ។ លោកថា លោក **ហេង ពៅ** ដែលកាលនោះលោកនៅជាស្នងការរងក្រុងភ្នំពេញ បានដឹងរឿងឃាតកម្មលើលោក **ជា វិជ្ជា** មេដឹកនាំកម្មករ ។ ប៉ុន្តែក្រោយមកទៀតលោក **ហេង ពៅ** បាននិយាយនៅសាលាដំបូងក្រុងភ្នំពេញថា លោក **ប៊ន សំណាង** និង **សុខ សំអឿន** មិនមែនជាឃាតករទេ លោកបន្តទៀតថា ប៉ូលីសមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចាប់ឃាតករ ប៉ុន្តែដោយសារប្រទេសយើងប្រព័ន្ធតុលាការយុត្តិធម៌មិនមានឯករាជ្យ ទើបធ្វើឱ្យសមត្ថកិច្ចប៉ូលីស ទាហាន ដែលមានចំណេះដឹងមានការសោកស្តាយដោយពួកគេមិនបានប្រើប្រាស់វិជ្ជាជីវៈរបស់គេ ។

នៅក្នុងពីធីដង្ហែរកំរងផ្កាគោរពវិញ្ញាណក្ខន្ធលោក **ជា វិជ្ជា** នោះដែរ គេសង្កេតឃើញឥស្សរជនជាន់ខ្ពស់នៃចលនានយោបាយប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរគឺ លោក **កឹម សុខា** និង លោក **សម រង្ស៊ី** ដើរប្រកៀកប្រកិតគ្នាក្នុងហ្វូងមហាជនដ៏ច្រើនកុះករ ។ ក្នុងនោះលោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស បានមានប្រសាសន៍ថា វិញ្ញាណក្ខន្ធ លោក **ជា វិជ្ជា** ស្ថិតនៅជាប់ជានិច្ចជាមួយអ្នកតស៊ូ អ្នកប្រជាធិបតេយ្យមិនអាចបាត់រលត់ដរាបណានៅរកមុខឃាតករមិនទាន់ ឃើញទេយើងនៅតែធ្វើការទាមទារនៅតែធ្វើការតស៊ូដើម្បីស្វែងរកមុខឃាតករពិតប្រាកដ ។

លោក **កឹម សុខា** បានសង្កត់ធ្ងន់ថាក្នុងនាមតំណាងរាស្រ្តរបស់គណបក្សសិទ្ធិមនុស្សលោកសូមរាជរដ្ឋាភិបាល ជាពិសេសព្រះមហាក្សត្រផ្តល់កិត្តិយសដល់វិញ្ញាណក្ខន្ធលោក **ជា វិជ្ជា** ជាវីរៈបុរសនៅក្នុងប្រទេសកម្ពុជា ។ លោក **សម រង្ស៊ី** ប្រធានគណបក្សសម រង្ស៊ី មានប្រសាសន៍ថាអស់រយៈពេល៥ឆ្នាំ ហើយដែលរដ្ឋាភិបាលអាជ្ញាធរនៅតែរកមុខឃាតករមិនឃើញ ឬក៏អាជ្ញាធរ

មិនបង្ហាញឆន្ទៈថា ចង់រកមុខជនដៃដល់ និងអ្នកនៅពីក្រោយខ្នងមកផ្តន្ទាទោសតាមច្បាប់ ។ លោក **សម រង្ស៊ី** បានបញ្ជាក់ទៀតថា នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ពេលនោះសភាពការណ៍នឹងប្រែប្រួល ហើយជនឧក្រិដ្ឋពិតជាគេរើកមុខហើយអ្នកដែលបានសមគំនិតក៏ត្រូវគេរើកមុខ និងយកទៅផ្តន្ទាទោសតាមច្បាប់ផងដែរ ។

## កម្មករជាង៧០០០នាក់ធ្វើកូដកម្មទាមទារប្រាក់ខែទី១៣ពីថៅកែរោងចក្រ

កម្មករនៅរោងចក្រយ៉ុងវ៉ាទី១ និងទី២ ប្រមាណ៧០០០នាក់បាន ប្រតិកម្មទៅនឹងអាជ្ញាធរប៉ូលីសខេត្តកណ្តាល ដែលបានប្រើអំពើហិង្សាចាប់បោកកម្មករ បាញ់ទឹកសំអុយ និងឧស្ម័នពុលទៅលើកម្មករ ខណៈពេលកម្មករទាំងនោះបាន ធ្វើកូដកម្មតវ៉ាទៅនឹងថៅកែរោងចក្រយ៉ុងវ៉ា ទាមទារឱ្យបើកប្រាក់ខែទី១៣ ប៉ុន្តែថៅកែរោងចក្រមិនព្រមបើកខែទី១៣ឱ្យកម្មករ ។

កម្មការិនីម្នាក់នៅរោងចក្រយ៉ុងវ៉ាបាននិយាយថា កម្មករទាំងអស់បានធ្វើកូដកម្មនៅមុខរោងចក្រ ដើម្បីឱ្យនៅតែបើកប្រាក់ខែទី១៣ឱ្យ ។ លុះក្រោយមកក៏មានអាជ្ញាធរប៉ូលីសបានមកឈរយាមទទាម និងបាញ់ទឹកសំអុយ ឧស្ម័នពុល និងវ៉ៃកម្មករម្នាក់រងរបួសបែកក្បាលទៀតផង ។ ពួកនាងធ្វើកូដកម្មនេះចង់ឱ្យនៅតែរោងចក្របើកប្រាក់ខែទី១៣បានន័យថា ប្រាក់អំណាចឆ្នាំក្នុងម្នាក់ទទួលបានយ៉ាងហោចណាស់ក៏៥០ដុល្លារដែរ ។ រៀងរាល់ឆ្នាំកម្មករតែងតែទទួលបានប្រាក់ខែទី១៣នេះ តែឆ្នាំនេះក្រុមកម្មករទាំងអស់មិនទទួលបាននោះទេ ។

**សុន ផល្លា** ប្រធានសហជីពកម្មករ ស៊ីខាឌូ នៃរោងចក្រយ៉ុងវ៉ា បានឱ្យដឹងថាវិវាទកើតឡើងនេះទាក់ទងនឹងប្រាក់ ខែទី១៣ ពីព្រោះថា រៀងរាល់ឆ្នាំក្រុមហ៊ុនតែងតែប្រាក់ខែទី១៣នោះឱ្យដល់កម្មករទាំងអស់ ។ ប៉ុន្តែឆ្នាំនេះដល់ថ្ងៃបើកប្រាក់ខែ ស្រាប់តែក្រុមហ៊ុនបានហៅកម្មករទៅប្រជុំដោយប្រាប់ថា ក្រុមហ៊ុនមានវិបត្តិសេដ្ឋកិច្ច ដូច្នេះប្រាក់ខែទី១៣ មិនអាចបើកជូនកម្មករទេ ហើយនាងបន្តថា កូដកម្មនេះមានកម្មការិនីរងរបួស៣នាក់ ។

លោក **លី តាំ** ប្រធានចលានកម្មករនៃគណបក្សសិទ្ធិមនុស្ស បានសង្កត់ធ្ងន់ថា អាជ្ញាធរប្រើអំពើហិង្សាមកលើកម្មករដែលមានតែដៃទទេរ និងប្រើសកម្មភាពឃោឃៅ អមនុស្សធម៌ហើយនេះក៏ជាការរំលោភសិទ្ធិរបស់កម្មករផងដែរ ។

## ឆ្នាំ២០០៨កំណើនវិវាទដីធ្លីនៅខេត្តកំពតមានការកើនឡើង

អ្នកភូមិកសិករជាង២០គ្រួសារ នៅឃុំក្រឡាញ់ ស្រុកអង្គរជ័យ ខេត្តកំពតបានតវ៉ារឿងដីធ្លី នៅសាលាឃុំក្រឡាញ់ ដោយពួកគាត់បានចោទលោក **មាស ហេង** មេភូមិកសិករថា មិនធ្វើប្លង់កម្មសិទ្ធិដីធ្លីឱ្យពួកគាត់ និងទារលុយចំនួន៣០ម៉ឺនរៀលជាថ្នូរ និងការធ្វើប្លង់កម្មសិទ្ធិ ។

អ្នកភូមិកសិករម្នាក់ក្នុងចំណោមជាង ២០ គ្រួសារដែលរងគ្រោះបាននិយាយថា មេភូមិមិនធ្វើប្លង់ធ្វើបង្កាន់ដៃដីធ្លី ជាង៥ហិកតាឱ្យប្រជាពលរដ្ឋ ២២គ្រួសារនោះទេ ។ ដោយសារមេភូមិទុកដីនោះជាដីរបស់រដ្ឋ ហើយដីស្រែនោះប្រជាពលរដ្ឋបានកាន់កាប់តាំងពីឆ្នាំ ១៩៨០ មកម្ល៉េះ ។ គាត់ឆ្លល់ថា ដីនៅជុំវិញអ្នកភូមិ២២គ្រួសារមានប្លង់កម្មសិទ្ធិស្របច្បាប់ ប៉ុន្តែពួកគាត់២២គ្រួសារបែរជាមេភូមិមិនធ្វើប្លង់កម្មសិទ្ធិឱ្យទៅវិញ ។

គាត់ថា នៅពេលសុរិយោដីស្រុកអង្គរជ័យមកធ្វើប្លង់កម្មសិទ្ធិនៅក្នុងកំឡុងខែមករានេះ មេភូមិបដិសេធមិនឱ្យធ្វើដោយគាត់ថា បើប្រជាពលរដ្ឋឱ្យលុយគាត់៣០ម៉ឺនរៀលក្នុងមួយគ្រួសារទើបគាត់ឱ្យវាស់ដីឱ្យ ។

ស្ត្រីនៅភូមិកសិករម្នាក់ទៀតក៏បានបញ្ជាក់ថា សុរិយោដីស្រុកបានមកវាស់វែងដីនោះដើម្បីធ្វើប្លង់កម្មសិទ្ធិ ឱ្យអ្នកភូមិប៉ុន្តែលោកមេភូមិបានបដិសេធដោយមកទារលុយកាលពីមុន ១៧០ដុល្លារតែក្រោយមកទារត្រឹម៣០ម៉ឺនរៀលវិញ ។ គោលបំណងដែលប្រជាពលរដ្ឋតវ៉ានៅសាលាឃុំក្រឡាញ់ គឺក្នុងគោលបំណងចង់រក្សាដីស្រែរបស់ពួកគាត់ឱ្យនៅដដែលពី ព្រោះគាត់ចាត់ទុកថាជាដីស្រែនោះជាឆ្នាំងបាយប្រចាំថ្ងៃរបស់ពួកគាត់ប៉ុន្តែ បើវាបាត់បង់តើគាត់ហ្នឹងបានអ្វីសំរាប់ប្រកប របរបចិញ្ចឹមជីវិតទៀត ។

យើងមិនអាចសុំការបំភ្លឺជុំវិញក្តីក្តាំរឿងដីធ្លី ដែលអ្នកភូមិចោទ លោក **មាស ហេង** មេភូមិកាន់កាប់ថា មិនធ្វើប្លង់កម្មសិទ្ធិ និងទារលុយ៣០ម៉ឺនរៀលបានទេ នៅព្រឹកថ្ងៃនេះដោយសារមេភូមិរូបនោះកំពុងប្រាស័យទាក់ទង តាមប្រព័ន្ធទូរស័ព្ទពលកថា ពិបាកទាក់ទង ក្រោយមកលោក **មាស ហេង** ក៏បានបិទទូរស័ព្ទយ៉ាងទាន់ហន់ ។ ទោះជាលោក មេភូមិកសិករមិនបានឆ្លើយបំភ្លឺក៏ដោយក៏សកម្មជនជាន់ខ្ពស់គណបក្សសិទ្ធិមនុស្ស នៅខេត្តកំពតដែលបានចុះដល់កន្លែងកើតហេតុបញ្ជាក់ថា ប្រការដែលមេភូមិមិនព្រមធ្វើប្លង់កម្មសិទ្ធិឱ្យប្រជាពលរដ្ឋ២០គ្រួសារ ។ ទំនងជាមេភូមិទុកដីទាំងនោះ សំរាប់ផលប្រយោជន៍បុគ្គលខ្លួនគាត់ផ្ទាល់ ពីព្រោះចាប់ពីឆ្នាំ១៩៨៣ ប្រជាពលរដ្ឋជាងម្ភៃគ្រួសារបានចាប់បង់ពន្ធជូនរដ្ឋ ត្រឹមត្រូវតែមកដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៦ មន្ត្រីសុរិយោដីស្រុកមកវាស់វែងធ្វើប្លង់កម្មសិទ្ធិឱ្យប្រជាពលរដ្ឋ តែលោក **មាស ហេង** បដិសេធ លុះដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ លោកមេភូមិកសិករ បានទារលុយពីអ្នកភូមិក្នុង១គ្រួសារចំនួន ៣០ម៉ឺនរៀល ក្នុងការធ្វើប្លង់កម្មសិទ្ធិជូនប្រជាពលរដ្ឋ ។

សកម្មជនគណបក្សសិទ្ធិមនុស្សបានបន្តថា មានប្រជាពលរដ្ឋ១២គ្រួសារផ្សេងទៀតនៅក្នុងភូមិជាមួយ ប្រជាពលរដ្ឋ២២គ្រួសារដែរនេះក៏មានបញ្ហាផ្ទាល់ខ្លួន ដូចគ្នានេះដែរដោយសារលោកមេភូមិបានយកលុយក្នុង១គ្រួសារចំនួន២០០០០រៀល ដើម្បីធ្វើប្លង់កម្មសិទ្ធិ ប៉ុន្តែប្រជាពលរដ្ឋទន្ទឹងរង់ចាំ យកប្លង់កម្មសិទ្ធិយូរហើយ នៅតែមេភូមិមិនទាន់យកឱ្យពួកគាត់ទៀត ។ លុះក្រោយមកខ្លាចរឿងរ៉ាវនោះបែកការណ៍ ទើបមេភូមិសុខចិត្តប្រគល់លុយចំនួន ២០០០០ រៀលឱ្យទៅប្រជាពលរដ្ឋវិញ ។

## អាជ្ញាធរនៅតែមានការរើសអើង និងប្រកាន់និន្នាការនយោបាយ

អាជ្ញាធរឃុំប្រាមយ៉ាម និងប៉ុស្តិ៍នគបាលរដ្ឋបាលឃុំប្រាមយ៉ាម ក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាមបាន រងការចោទប្រកាន់ថា មានភាពរើសអើងគណបក្សនយោបាយ បើទោះជាការបោះឆ្នោតបានបញ្ចប់ប្រមាណ ៧ខែទៅហើយក្តី ។

ភរិយាលោក **កេន ផា** ជាសកម្មជននៅភូមិជើងដឹកឃុំប្រាមយ៉ាមដែលកាលពីថ្ងៃទី០៦ ខែមករា កន្លងទៅនេះដីធ្លីរបស់រងការរំលោភបំពាន ពីអ្នកភូមិដែលមានផ្ទះសំបែងនៅក្បែរខាងគ្នា ហើយភាគីបង្កហេតុនេះក៏បានបង្ករបួសស្នាមមកលើប្តីរបស់នាង ។ ប៉ុន្តែពេលដែលគ្រួសារលោកដាក់បណ្តឹងទៅប៉ុស្តិ៍នគរបាលឃុំប្រាមយ៉ាមបែរជាសមត្ថកិច្ចធ្វើព្រងើយកន្តើយ ចំណែកអាជ្ញាធរឃុំ ក៏បានសន្យាផងដែរថា នឹងដោះស្រាយជំល្លោះដីនោះឱ្យគ្រួសាររបស់នាងខណៈពេលវិវាទ កើតឡើងប៉ុន្តែចាប់តាំងពីថ្ងៃទី០៦ ខែមករាមកដល់ថ្ងៃនេះអាជ្ញាធរនៅតែមិនទាន់ដោះស្រាយនៅឡើយ ។

សកម្មជន គណបក្សសិទ្ធិមនុស្ស ម្នាក់ទៀតនៅភូមិជើងទឹកបានសង្កត់បន្ថែមសមត្ថកិច្ច និងអាជ្ញាធរឃុំប្រាមយ៉ាម នៅតែបង្ហាញចរិករើសអើង ចំពោះប្រជាពលរដ្ឋដែលគាំទ្រគណបក្សសិទ្ធិមនុស្ស ។ យើងមិនអាចសុំសេចក្តីអធិប្បាយពីលោក **ឡេង នាម** មេឃុំប្រាមយ៉ាងបានទេនៅថ្ងៃនេះ ប៉ុន្តែលោក **ថា ម៉ាច** អនុប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំប្រាមយ៉ាមបានបញ្ជាក់ថា ករណីបណ្តឹងរបស់លោក គឺមិនមានអ្វីធ្ងន់ធ្ងរនោះទេ ហើយនៅពេលលោកកោះហៅភាគីទាំងពីរមកសាកសួរភាគីទាំងពីរ នោះមិនមានសាក្សីរៀងៗខ្លួនដូច្នោះសមត្ថកិច្ចពិបាកក្នុងការដោះស្រាយ ។ ទាក់ទងទៅនឹងការរើសអើងនយោបាយលោក **ថា ម៉ាច** បានបដិសេដ និងច្រានចោលចំពោះពាក្យចោទប្រកាន់នេះ លោក **ហង្ស សុវ៉ាត** មន្ត្រីសំរបសំរួលនៃសមាគមអាដហុក នៅខេត្តកំពង់ចាមបានចង្អុលបង្ហាញថា ស្ថានភាពនៃការរើសអើងរវាង អាជ្ញាធរមូលដ្ឋានជាមួយប្រជាពលរដ្ឋមានការថយចុះច្រើន ប៉ុន្តែរូបភាពនៃការរើសអើងនយោបាយនៅតែកើតមាន តែនៅដំណាក់ការការបោះឆ្នោតការរើសអើងកើតមានច្រើន ។ លោកថា អាជ្ញាធរប្រមាណ ៩៥% ហើយដែលស្ថិតនៅក្នុងគណបក្សកាន់អំណាច ហើយអាជ្ញាធររកមានក្រមសីលធម៌ ពីព្រោះអាជ្ញាធរថា របស់រដ្ឋ ដូច្នេះធ្វើអ្វីៗឱ្យបានស្មើភាព ។ ការរើសអើងនយោបាយនេះធ្វើឱ្យកើតមានបញ្ហាដល់សង្គមការប្រេះឆាគ្នាចំណងសាមគ្គីភាព ពីព្រោះស្រុកទេសយើងកំពុងរងការមើលងាយពីប្រទេសជិតខាង អ៊ីចឹងហើយនាំឱ្យប្រជាពលរដ្ឋយើងទន់ខ្សោយ ។

ទោះបីយ៉ាងណាក៏ដោយអាជ្ញាធរមូលដ្ឋានដែលស្មោះត្រង់ និងគណបក្សកាន់អំណាចតែតែលាបពណ៌ប្រជាពលរដ្ឋ ខ្មែរថាបក្សនេះបក្សនោះ ហើយអាជ្ញាធររមែងតាបសង្កត់ទៅប្រជាពលរដ្ឋណាដែលមិនគាំទ្របក្សរបស់ខ្លួន និងមិនយកចិត្តទុកដាក់នៅពេលពួកគាត់ទៅពឹងពាក់ព័ន្ធអាជ្ញាធរទាំងនោះ ។

## ប្រជាពលរដ្ឋជាង២០០គ្រួសាររងការបាត់បង់ដីធ្លី

សង្គមស៊ីវិល អ្នកនយោបាយនៅតែបន្តការរិះគន់ធ្ងន់ៗទៅលើអាជ្ញាធរកងរាជអាវុធហត្ថ នៅខេត្តកណ្តាលដែលស៊ីឈ្នួលយាមការពារដីធ្លីឱ្យក្រុមហ៊ុននេសាទអភិវឌ្ឍន៍ ហើយមានការបាញ់ប្រហារមកលើអ្នកភូមិ២នាក់នៅក្នុងឃុំកណ្តោក និងឃុំអំពៅព្រៃ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

នៅពេលដែលអ្នកភូមិប្រហែល២០០នាក់ បានព្យាយាមបញ្ឈប់ត្រាក់ទ័រដែលឈូសឆាយដីធ្លីរបស់ពួកគាត់នោះ មន្ត្រីកងរាជអាវុធហត្ថបានបាញ់កាំភ្លើង ទៅលើយុវជនអាយុ២៨ឆ្នាំចំដៃ និងចំពោះ ហើយយុវជន **ហាន** ប្រុស អាយុ ២៣ ចំចង្កេះ ។

លោក **ម៉ែន មករា** មន្ត្រីស៊ើបអង្កេតសមាគមអាដហុក នៅខេត្តកណ្តាលបានប្រាប់ថា ករណីដែលមន្ត្រីប៉េអឹមបានបាញ់ប្រហារទៅលើប្រជាពលរដ្ឋស្លូតត្រង់ វាជារឿងខុសច្បាប់រួចទៅហើយ ពីព្រោះអាវុធគេប្រើសំរាប់បាញ់ខ្មាំងមិនមែនបាញ់ប្រជាពលរដ្ឋស្លូតត្រង់នោះទេ គួរណាស់តែអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ចាត់វិធានការសំរបសំរួលដើម្បីបញ្ចៀស ឱ្យបានពីការប្រើអំពើហិង្សា ។ ប្រសិនបើដីនោះជាដីរបស់ក្រុមហ៊ុនដែរនោះ គួរតែក្រុមហ៊ុន **ហេង អភិវឌ្ឍន៍** ទៅចរចា និង បង្ហាញហេតុផលច្បាស់លាស់ទាក់ទងនឹងការកាន់កាប់ដីធ្លី ។ ប៉ុន្តែក្រុមហ៊ុនបែរជាមិនបង្ហាញបញ្ហានេះ ហើយមកដាក់គ្រឿងចក្រឈូសឆាយដីធ្លីទៅវិញនោះគឺជារឿងមួយខុសច្បាប់ ។

លោកស្រី **ទៀង ច័ន្ទហេង** ម្ចាស់ក្រុមហ៊ុន **ហេង អភិវឌ្ឍន៍** បានគូសបញ្ជាក់ថា ដីដំលោះជាកម្មសិទ្ធិរបស់គាត់ដោយបានទិញពីប្រជាពលរដ្ឋឃុំកើប កណ្តោក ព្រៃស្លែង និងអំពៅព្រៃបឹង ហើយភាគីម្ខាងទៀតដែលមកតវ៉ាដំលោះ នោះពួកគាត់ស្ថិតនៅលើទំនប់៩៤ ដែលលោកស្រីបានធ្វើតាំងពីឆ្នាំ១៩៩៧ហើយដីនៅទីនោះលោកស្រីបានទិញពី ប្រជាពលរដ្ឋតាំងពីឆ្នាំ ១៩៩៩ -៩៤-៩៧ ជាផ្ទៃដីទំហំជិត១ពាន់ហិកតា ។

ទាក់ទងទៅនឹងសំណួរថា ហេតុអ្វីបានជាក្រុមហ៊ុន **ហេង អភិវឌ្ឍន៍** មានកងកំលាំងប្រដាប់អាវុធមកការពារដីធ្លីឱ្យក្រុមហ៊ុន ហើយ មានការបាញ់ប្រហារទៅលើអ្នកភូមិទៅវិញ ?

លោក **ប៉ែន សុវណ្ណ** អតីតនាយករដ្ឋមន្ត្រីសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជាកំឡុងឆ្នាំ១៩៨០ នោះបានមានប្រសាសន៍ថា សព្វថ្ងៃនេះអ្នកមានអំណាច អ្នកមានលុយគេហ៊ានធ្វើអ្វីៗទាំងបំពានលើប្រជាពលរដ្ឋក្រីក្រទាមទារសិទ្ធិកម្មសិទ្ធិស្របច្បាប់ ។ កងកំលាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ហ៊ានបំពានមកលើប្រជាពលរដ្ឋដោយសារហេតុអ្វី គឺដោយសារតែអ្នកមានលុយ អ្នកមានអំណាច។ ទាហានប៉ូលីសមួយចំនួនបានក្លាយទៅជាទាហ៊ានឯកជន ប៉ុន្តែជីវភាពរស់នៅទទួលបានប្រាក់ខែពីរដ្ឋ ។



| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| លោក | ម៉ី សាន | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| កញ្ញា | គង់ វណ្ណា | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |



**បញ្ហាទំនាស់ដីធ្លីនៅតែជាភាពចំរូងចំរាស់នៅក្នុងប្រទេសកម្ពុជា!**